# វិធី តំលើង/ប្រើប្រាស់ ស្កេភ (Skype)
# ជា អក្សរខ្មែរ ១០០% សំរាប់ ញ៉ែស្វ៊ីវឌ្វីប
# រំភើយឥតគិតថ្លៃ សារហ៊េស/សំលេង/វីឌីអូ




ធ្នូ ២០, ២០០៩ - ឈរ វ៉ាណា

**ស្កេភី** (Skype) ជាកម្មវិធី ជជែកឆ្លើយឆ្លងទាន់ចិត្ត ឥតគិតថ្លៃ លើ បណ្តាញអិនធើណែត តាមរយៈខំព្យូទ័រ ឬ ទូរសព្ទចល័ត។

បច្ចុប្បន្ន **ស្កេភី** ត្រូវបានប្រើប្រាស់ឆ្លើយឆ្លង ជា សាររហ័ស / សំលេង/វីឌីអូ និង អាចផ្ញើរវាងគ្នា ត្រឹមមួយប៉ប្រិចភ្នែក រាល់ប្រភេទ ឯកសារ...ឧទាហរ សំបុត្រកំណើត, សំបុត្រការ ទោះអ្នកឆ្លើយឆ្លង នៅឆ្ងាយគ្នា ដល់ជើងមេឃ ឬ នៅចុងម្ខាង នៃផែនដី។




ប្រាកដណាស់, ប្រទេសនីមួយ មានព្រំដែនរៀងខ្លួន, រីឯអិនធើណែត ជាពិសេស **ស្កេភី** គ្មានព្រំដែន ទោះ លើអាកាស ក្រោមសមុទ្រ។ វា ជ្រៀតចូលទៅ គ្រប់ទិសទី/គ្រប់ប្រទេស មិនថា ប្រទេសផ្តាច់ការ យោធា (ប្រទេសភូមា), ឬ ពពួកប្រទេស កុំមុយនីស្តសំណល់ (ប្រទេស ចិន, ប្រទេសលាវ, ប្រទេសយួន, ប្រទេសខរៀខាងជើង, ប្រទេសគូប៊ី(Cuba)) ឬ ប្រទេសកំពុងអនុវត្តនយោបាយ កំអែល កុំមុយនីស្តផ្តាច់ការ (ប្រទេសខ្មែរ)។




## ➡ អ្នក ណា អាច ប្រើ ប្រាស់ ស្កេភី ?

គ្រប់ស្រទាប់មហាជន មិនថា ប្រុស ឬ ស្រី, មិនថា ប្តី ឬ ប្រពន្ធ, មិនថា កូនក្មេង ឬ មនុស្សធំ, មិនថា ក្មេងចំណាស់ ឬ ចាស់ជំទាវ, មិនថា សង្ឃ ឬ ដូនជី,... ច្រើនទៀត សុទ្ធសឹង អាចប្រើប្រាស់ **ស្កេភី** តាមចង់។

## ➡ ប្រើប្រាស់ ស្កេភី មានប្រយោជអ្វី ? ញ៉ែគ្នា !!!

ញ៉ែរកស្នេហា, ញ៉ែរកការងារ, ញ៉ែរកពាណិជ, ញ៉ែរក ចំណេះ, ញ៉ែរកបទពិសោធ, ញ៉ែសួរសុខទុក, ញ៉ែ ស្វែងអារម្មណ៍.., ..តាមតែ របៀបញ៉ែរៀងខ្លួន។

ដើម្បី ចូលសាច់រឿង, **ខ្មែរអាយធីសំរាប់អ្នក** ណែនាំហូរហែរ វិធីតំលើង/ប្រើប្រាស់ **ស្កេភី** ជា ក្រមអក្សរខ្មែរយូនីកូដ-នីដា លើ **វិនដោស្ស ៧** សំរួលការញ៉ែ ឬ ការឆ្លើយឆ្លង សំដៅបង្កើនចំណេះ ជាអក្សរកំណើត សំរាប់គ្រប់កូនខ្មែរ។

# ជំហាន ១ – ទាញយក/តំលើង ស្កេភ និងបញ្ចូល កញ្ចប់អក្សរខ្មែរ នៅក្នុង វា

## ១.១ - ទាញយក/តំលើង ស្កេភី

ចុចទីនេះ៖ ទាញយក/តំលើង ស្កេភី (Skype) លើខំព្យូរើ របស់អ្នក, បន្ទាប់ អ្នកត្រូវតែ ចុចហូរហែរ លេខ ១,..., ៩ ខាងក្រោម៖




## ១. ២ - បញ្ចូល កញ្ចប់អក្សរខ្មែរ ទៅក្នុង ស្កេភី

ចុចទីនេះ៖ ទាញយក/រក្សាទុក កញ្ចប់អក្សរខ្មែរ ក្នុងខំព្យូរើ របស់អ្នក, រួច អនុវត្ត ១០, ..., ១៣ សំរាប់បញ្ចូលវា ទៅ ស្កេភី។






# ជំហាន ២ – កំណត់ទំរង់ ស្កេភ (Skype) និង កំណត់ទំរង់ វិនដោស្ស ៧ (Windows 7)

បន្ទាប់ការតំលើង ស្កេភី និង បញ្ចូលកញ្ចប់អក្សរខ្មែរ សំរាប់ វា, ផ្ទាំងប្រទាក់ (Interface) ស្កេភី បានបង្ហាញចេញ ទាំងស្រុង អក្សរខ្មែរ សំរួលបំរើប្រាស់ស្កេភី សំរាប់កូនខ្មែរគ្រប់រូប។

ជំហាន ២ ជាជំហាន សំរាប់ធ្វើភាពប្រពៃជាង ការបង្ហាញ ក្រមអក្សរខ្មែរយូនីកូដ-នីដា លើស្កេភី។

## ២.១ - ចុចទាញយក/រក្សាទុក និង រត់ កូនកម្មវិធី fixwindows7 សំរាប់ដកចេញ ក្រមអក្សរ DaunPenh ពី Windows 7

ចុច ទាញយក/រក្សាទុក កូនកម្មវិធី fixwindows7 របស់ Nokorsoft ក្នុងខំព្យូរើ របស់អ្នក, និង អនុវត្តហូរហែរ ខាងក្រោម៖













---

## បញ្ជាក់៖

- ត្រូវតែតំលើង ក្រមអក្សរខ្មែរយូនីកូដ-នីដា មុនតំលើងស្កេភី, ចុចអាន វិធីតំលើង ក្រមអក្សរខ្មែរយូនីកូដ-នីដា លើ វិនដោស្ស ៧
- តំលើង ស្កេភី អាចត្រូវបានអនុវត្ត ត្រឹមលើ វិនដោស្ស ៧ ឬ វិនដោស្សវិស្តា

## មើលផងដែរ៖

- http://khmeritforyou.blogspot.com
- http://deumtnout.wordpress.com
- វិធី បង្កើតបណ្តាញសង្គម ជាអក្សរខ្មែរ ១០០%

## ២.២ - កំណត់ទំរង់ ស្តេភី សំរាប់ ឆ្លើយឆ្លង សាររហ័ស (instant messaging) ជាក្រមអក្សរខ្មែរ យូនីកូដ

ស្តេភី ប្រើប្រាស់ជាលំនាំដើម ក្រមអក្សរ Tahoma ទំហំ 6 ចំណុច។ អាចឆ្លើយឆ្លង សាររហ័ស (Instant messaging) ក្រមអក្សរខ្មែរយូនីកូដ-នីដា, អ្នកត្រូវតែ ផ្លាស់ប្តូរក្រមអក្សរ ជា Khmer OS System 11 ចំណុច។ វិធីអនុវត្ត ត្រូវបានណែនាំ ហូរហែរ ខាងក្រោម។


















## ២.២ - កំណត់ទំរង់ វិនដោស្ស ៧ សំរាប់ បង្ហាញចេញច្បាស់ រាល់អក្សរខ្មែរ លើ ផ្ទាំងប្រទាក់ (Interface) របស់ ស្កេភី




→




អាចកែប្រែ ពីអក្សរតូច មកអក្សរធំ, អ្នកអាចអនុវត្ត ហូរហែរ ពីលេខ ១២, ..., ១៧ ខាងក្រោម។
















**ខ្មែរអាយធីសំរាប់អ្នក**

**ជាពន្លឺចំណេះខំព្យូរើ សំរាប់កូនខ្មែរ !!!**

# ក្តារចុចពុម្ពអក្សរ ខ្មែរយូនីកូដ

## Khmer Unicode Keyboard NiDA Standard

ទាញយក ក្រមអក្សរខ្មែរពី http://www.khmeros.info/drupal

J ្ ← សញ្ញា សំរាប់ដាក់ជើង

ស + ំ + រ + េ + ច → សំរេច

ប + ្ + រ + ោះ → ប្រោះ

Ctrl+Alt ឬ Alt Gr (ឆ្លាស់) → ឫ ឬ ← ប្តូរ
R រ ← ធម្មតា

ប្តូរ + ចន្លោះទទេ = ចន្លោះទទេ(ពេល វាយអក្សរខ្មែរ)

ប្តូរ + ជំនួស = ក្តារចុច ពី ខ្មែរ ⇄ អង់គ្លេស

## ក្តារចុច QWERTY

http://khmeritforyou.blogspot.com ជួយបង្កើន ចំណេះកុំព្យូទ័រ សំរាប់អ្នក




បានបន្ទាន់សម័យ ថ្ងៃ 30/10/2009

# ក្ដារចុចពុម្ពអក្សរ ខ្មែរយូនីកូដ

## Clavier Khmer Unicode

NiDA Standard

ទាញយក ក្រុមអក្សរខ្មែរ ពី http://www.khmeros.info/drupal

ញ / J ◌្ ← សញ្ញា សំរាប់ដាក់ជើង

ស + ◌ំ + រ + េ◌ + ច → សំរេច

ប + ◌្ + រ + េ◌ាះ → ប្រោះ

Ctrl+Alt ឬ Alt Gr (ឆ្លាស់) → ឫ ឬ ← ប្តូរ

R រ ← ធម្មតា

ប្តូរ + ចន្លោះទទេ = ចន្លោះទទេ (ពេល វាយអក្សរខ្មែរ)

ប្តូរ + ជំនួស = ក្ដារចុច ពី ខ្មែរ ⇄ អង់គ្លេស

# ក្ដារចុច AZERTY

http://khmeritforyou.blogspot.com ជួយបង្កើន ចំណេះខំព្យូរី សំរាប់អ្នក




បានបន្ទាន់សម័យ ថ្ងៃ 30/10/2009